ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៤

ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣

<u>សាលដីកា</u>

លេខ : ៤១៦ (គ)

ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣

# <u>សាលដីកា</u>

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣ ។

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

-ដើមចោទឈ្មោះ [redacted] សុជាតា (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥០ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិគោករដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-ចុងចម្លើយឈ្មោះ [redacted] សំអឿន ហៅ ចូច (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិសែសិន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

<u>**កម្មវត្ថុបណ្តឹង**</u> ៖ ប្តឹងទាមទារប្រាក់ ។

## អំពីអង្គហេតុ និង ចំណុចទទាន :

ក - <u>**អំពីអង្គហេតុជាមូលហេតុនៃការទាមទារ**</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ របស់ដើមចោទឈ្មោះ [redacted] សុជាតា បានអះអាងថា : នៅខែកញ្ញា ឆ្នាំ២០១១ ឈ្មោះ [redacted] សំអឿន ហៅ ចូច បានទទួលផ្ញើដំបូលផ្ទះ



... សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, ភ្នំពេញ ... Sothearos Blvd Sangkat Chatomuk Khan Daun Penh, Cambodia

របស់ខ្លួន ដោយដំបូលផ្ទះនេះប្រក់ក្បឿង ភីប៉ារ៉ូស៊ីម៉ង់ នៅពេលដំណើរការប្រក់ដំបូល កូនជាងរបស់ចុងចម្លើយធ្វើឱ្យខូចខាតក្បឿងរបស់ដើមចោទ។ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ចុងចម្លើយបានធ្វើកិច្ចសន្យាថា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ គាត់សងប្រាក់ឱ្យដើមចោទគ្រប់ចំនួន។ លុះដល់ថ្ងៃកំណត់សងប្រាក់មកដល់ ចុងចម្លើយមិនព្រមសងប្រាក់តាមកិច្ចសន្យាឡើយ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០២ -ខ- ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សំអឿន ហៅ ចូច សងការខូចខាតព្រំ និងក្បឿងទៅអោយដើមចោទឈ្មោះ [redacted] សុជាតា ជាប្រាក់បាតស្មើនឹង ១៤.៧២០ បាត (មួយម៉ឺនបួនពាន់ប្រាំពីររយម្ភៃបាតគត់) និងជម្ងឺចិត្តចំនួន ៧០០.០០០៛០០ គត់ (ចិតសិបម៉ឺនរៀលគត់) ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរតទៅ។ ការទាមទារសំណងជម្ងឺចិត្តលើសពីនេះរបស់ដើមចោទ ត្រូវច្រានចោល។

តាមមាត្រា ៣ , ២២ និង ១២១ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៣-សាលក្រមនេះ ធ្វើការទាញហេតុផល និងប្រកាសជាសាធារណៈចំពោះមុខគូភាគី។ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សំអឿន ហៅ ចូច ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ "ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសេចក្ដីសម្រេចនៃសាលក្រមទាំងមូល។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុជាតា ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ "ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសេចក្ដីសម្រេចនៃសាលក្រមទាំងមូល។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៨ -ក្រvញ- ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ក/ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុជាតា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

ខ/ច្រានចោលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សំអឿន ចោលជាអសារបង់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២ "ខ" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើកលែងតែចំណុចទី ១ ត្រង់សំណងការខូចខាតចំនួន ១៤.៧២០ បាត ត្រូវកែប្រែទៅជាចំនួន ៤៧.៦២០ បាត និង ២០០ ដុល្លារអាមេរិក ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ បើកផ្លូវប្តឹងសាទុក្ខរយៈពេលមួយខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

-បានឃើញបណ្តឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] សំអឿន ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ០៥ "ក្រVញ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលរបស់សាលដីកា។

ខ- <u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u>

-លោក [redacted] សំអឿន ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើការអះអាងថា ៖

ខ្លួនមិនសុខចិត្តនឹងការសំរេចរបស់សាលាឧទ្ធរណ៍ ព្រោះការកាត់សេចក្តីនៅសាលាឧទ្ធរណ៍ មានភាពអយុត្តិធម៌ ព្រោះខ្លួនត្រូវធ្វើបន្តពីជាងមុន។ ហើយខ្លួនត្រូវផ្សារដែកបន្ថែម និងប្រក់ ពេលខ្លួនរៀបព្រំ មេឃជិតភ្លៀង ខ្លួនប្រាប់គាត់ថា ព្រំមិនកើតទេ ព្រោះវាខូច តែគាត់បានហៅកូនជាងខ្លួនឱ្យឡើងព្រំ។ ក្បឿងដែលខូច យ៉ាងច្រើន ៥០ សន្លឹក ១ សន្លឹកតម្លៃ ៣៧ បាត ខ្លួនសុំសងតាមភស្តុតាងដែលមាន។ ពេលធ្វើកិច្ចសន្យាសងប្រក់ ខ្លួនមិនទាន់បានឃើញក្បឿងបែកទេ។ តម្លៃឈ្នួលប្រក់ ខ្លួនយកតែ ១៧០ ដុល្លារអាមេរិក ទេ។

-លោកស្រី [redacted] ជាចុងបណ្តឹងសាទុក្ខ បានធ្វើការអះអាងថា ៖

គាត់មិនដែលមកមើលកូនជាងគាត់ធ្វើទេ បណ្តោយអោយកូនជាងធ្វើតែឯង ហើយពេលភ្លៀងធ្វើឱ្យហូរស៊ីម៉ង់ត៍។ ឥឡូវប្រក់ហើយ តែរៀចចុះរៀចឡើង រើចុះរើឡើង ពេលព្រំ គឺព្រំទាំងអស់ក្បឿងដែលខូចមាននៅសល់ខ្លះ។ ពេលកូនជាង [redacted] សំអឿន ដាប់ចេញហើយ ទើបខ្លួនហៅជាងថ្មីមកធ្វើ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា ៖

ការជួសជុលនេះ មានការយោគយល់គ្នាទៅវិញទៅមក ហើយនៅសល់តែព្រំ។ ការជួសជុលផ្ទះ ពុំមានកិច្ចសន្យាជួសជុលផ្ទះទេ គឺធ្វើដោយផ្ទាល់មាត់។ អ្នកស្រី [redacted] សុជាតា គាត់បានបញ្ជាឱ្យកូនជាងធ្វើទាំងភ្លៀង និងយកសាប៊ូទៅដុសលាង ដែលគាត់ជាម្ចាស់ផ្ទះ ពុំមែនជាអ្នកបច្ចេកទេស

ឡើយ។ គាត់ប្ដឹងឧទ្ធរណ៍មកនេះ ទាមទារក្បឿង ១.៣០០ ក្បឿង តែសាលាឧទ្ធរណ៍សំរេចជាង ៤ ម៉ឺនបាត និង ២០០ ដុល្លារអាមេរិក។ កូនក្ដីខ្លួនមិនទាន់បានកំរៃឈ្នួលជាងផង គាត់ថែមទាំងប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្លួន។

សំណូមពរ : សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និងសុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចំលើយរបស់គូភាគី និងសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា: បណ្ដឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣ របស់លោក [redacted] សំអឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា: ការដែលសាលាឧទ្ធរណ៍សំរេចសេចក្ដីឱ្យលោក [redacted] សំអឿន សងសំណងការខូចខាតចំនួន ៤៧.៦២០ បាត និង ២០០ ដុល្លារអាមេរិក នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ៖

-គូភាគីបានចុះកិច្ចសន្យា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ សុខចិត្តសងការខូចខាតចំនួន ១៤.៧៦០ បាត ហើយកិច្ចសន្យានេះ នៅតែមានតម្លៃគតិយុត្តិដដែល ព្រោះគ្មានភាគីណាមួយប្ដឹងសុំរំលាយទេ។ យោងតាមមាត្រា ២២ នៃក្រិត្យច្បាប់ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា គូភាគីត្រូវតែអនុវត្តន៍ឱ្យបានទៀតទាត់ដោយខានមិនបាន។

-យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ ០៥ "ក្រVIញ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ ពុំទាន់ត្រឹមត្រូវតាមគតិច្បាប់នៅឡើយទេ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣ របស់លោក [redacted] សំអឿន។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០៥ "ក្រVIញ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់អ្នកស្រី [redacted] សុជាតា។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសនាសវនាការជាសាធារណៈ ទៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣។

-ឯកឧត្ដម [redacted] ប្រធាន

-លោក ចៅក្រម

-លោក ចៅក្រម

-លោក ចៅក្រម

-លោក ចៅក្រម

-លោក ក្រឡាបញ្ជី

---

បានឃើញ
ភ្នំពេញ ថ្ងៃទី ៧៦ ខែ តុលា ឆ្នាំ ២០១៣
ប្រធាន

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣
ក្រឡាបញ្ជី

[redacted]